ព្រឹទ្ធសភា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍
# ស្តីពី
# លទ្ធផលការងាររបស់ព្រឹទ្ធសភា
# ប្រចាំខែតុលា ឆ្នាំ២០១៤

នៅក្នុងខែតុលា ឆ្នាំ២០១៤នេះ ព្រឹទ្ធសភាបានបំពេញភារកិច្ចរបស់ខ្លួនដូចតទៅ៖

## ១.សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភា

### ១.១ សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម ប្រធានព្រឹទ្ធសភា បាន៖

-ពិនិត្យផ្តល់យោបល់លើសេចក្តីព្រាងច្បាប់ជូនគណៈកម្មការជំនាញព្រឹទ្ធសភាចំនួន ០៣ច្បាប់

-អនុញ្ញាតឲ្យឯកឧត្តមឯកអគ្គរដ្ឋទូតវៀតណាមប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ចូលជួបសម្តែងការគួរសម

-អនុញ្ញាតឲ្យឯកឧត្តម **សម រង្ស៊ី** និងលោកជំទាវ ចូលជួបសម្តែងការគួរសម

-ចុះហត្ថលេខាលើកំណត់ហេតុសង្ខេប និងកំណត់ហេតុពិស្តារ នៃការប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ នីតិកាលទី៣ចំនួន១០ច្បាប់ និងការប្រជុំព្រឹទ្ធសភា នីតិកាលទី៣ចំនួន១៨ច្បាប់

-ចុះហត្ថលេខាលើលិខិតផ្សេងៗចំនួន១៩លិខិត ។

### ១.២ ឯកឧត្តម សាយ ឈុំ អនុប្រធានទី១ព្រឹទ្ធសភា បាន៖

-អញ្ជើញដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន០២លើក និងកិច្ចប្រជុំវិសាមញ្ញព្រឹទ្ធសភាចំនួន០១លើក

-អនុញ្ញាតឲ្យគណៈប្រតិភូយុវជនកម្ពុជា ចូលជួបសម្តែងការគួរសម និងស្តាប់ប្រសាសន៍ផ្តាំផ្ញើដល់ក្រុមយុវជនកម្ពុជាចំនួន ២០រូប ដែលត្រូវបានចាត់តាំងទៅចូលរួមវគ្គបណ្តុះបណ្តាល (អ្នកដឹកនាំវ័យក្មេងអាស៊ានឆ្នាំ២០១៤) ដែលនឹងប្រព្រឹត្តទៅនៅទីក្រុងណានីង ខេត្តក្វាងស៊ី សាធារណរដ្ឋប្រជាមានិតចិន

-អញ្ជើញចូលរួមអមដំណើរសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា អញ្ជើញទៅគោរពវិញ្ញាណក្ខន្ធ និងបំពាក់គ្រឿងឥស្សរិយយសជូន

វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443 ទូរសារ (855 23) 211 446, E-mail: oum_sarith@camnet.com.kh

សពលោកព្រឹទ្ធាចារ្យ **ជុំ ហ៊ល** នៅគេហដ្ឋានរបស់សព ស្ថិតក្នុងសង្កាត់លេខ៣ ក្រុងព្រះសីហនុ

-អញ្ជើញជាអធិបតីបើកវេទិកាស្តីពី "ការបើកចំហព័ត៌មានសាធារណៈ ការដោះស្រាយបញ្ហារបស់ក្រុមប្រឹក្សាឃុំ សង្កាត់ និងសហគមន៍ក្នុងដំណើរឆ្ពោះទៅរកអភិបាលកិច្ចល្អ " ដែលរៀបចំដោយក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៧ រួមសហការជាមួយវិទ្យា ស្ថានសភាកម្ពុជា, វិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ,អង្គការម្ទប់បៃតង និងអង្គការ ជីវិតថ្ងៃថ្នូរ នៅសាលសិក្ខាសាលាបណ្ណាល័យ ព្រឹទ្ធសភា

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន១៥២ច្បាប់ ។

**១.៣ ឯកឧត្តម ទេព ងន អនុប្រធានទី២ ព្រឹទ្ធសភាបាន៖**

-អញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន០២លើក និងកិច្ចប្រជុំវិសាមញ្ញព្រឹទ្ធសភាចំនួន០១លើក

-អញ្ជើញដឹកនាំសមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាគោរពព្រះវិញ្ញាណក្ខន្ធ ព្រះបរមរតនកោដ្ឋ នៅព្រះបរមរូប ព្រះបរមរតនកោដ្ឋ

-អញ្ជើញចូលរួមជាកិត្តិយសក្នុងព្រះរាជពិធីរាប់បាត្រថ្វាយប្រគេនព្រះសង្ឃ ៩០អង្គក្នុងព្រះរាជពិធីបុណ្យគម្រប់២ឆ្នាំ នៃការសោយព្រះទីវង្គត់ព្រះបរមរតនកោដ្ឋ នៅក្នុងព្រះបរមរាជវាំង

-អញ្ជើញជាអធិបតីថ្លែងសុន្ទរកថាបើកសិក្ខាសាលាស្តីពី " ប្រវត្តិសាស្ត្រ និងបេតិកភ័ណ្ឌខ្មែរ " និង "ការត្រួតពិនិត្យផលិតផលគ្រឿងស្រវឹង"

-អញ្ជើញចូលរួមជាកិត្តិយសក្នុងជំនួបសំណេះសំណាល រវាងគណៈប្រតិភូសមាគមមិត្តភាពប៊្រុយណេ-ចិន ជាមួយឯកឧត្តម **ឯក សំអុល** ប្រធានសមាគមមិត្តភាពកម្ពុជា-ចិន

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន៦៧ច្បាប់ ។

**២.សម័យប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន ០២លើក ដើម្បី ៖**

ពិនិត្យ និងសម្រេចបញ្ជូនសេចក្តីព្រាងច្បាប់ចំនួន០៤ ទៅគណៈកម្មការជំនាញ និងទៅក្នុងរបៀបវារៈប្រជុំវិសាមញ្ញព្រឹទ្ធសភា៖

១-ពិនិត្យ និងសម្រេចលើសំណើរបស់គណៈកម្មការទី៦ព្រឹទ្ធសភា សុំដាក់សេចក្តីស្នើច្បាប់ធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា៧៦ និងមាត្រាទាំងឡាយពីជំពូកទី១៥ដល់ជំពូកទី១៦ថ្មីនៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ។

២-ពិនិត្យ និងសម្រេចលើសំណើរបស់គណៈកម្មការទី៣ព្រឹទ្ធសភា សុំដាក់សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើពិធីសារណាហ្គូយ៉ា ស្តីពីសិទ្ធិទទួលផលពីធនធានសេនេទិក

និងការបែងចែកផលប្រយោជន៍ ពីការប្រើប្រាស់ធនធានសេនេទិកដោយស្មើភាព និងសមធម៌នៃអនុសញ្ញាសហប្រជាជាតិស្តីពីជីវៈចម្រុះ ។

៣-ពិនិត្យ និងសម្រេចលើសំណើរបស់គណៈកម្មការទី៩ព្រឹទ្ធសភា សុំដាក់សេចក្តីព្រាងច្បាប់ស្តីពី វិសោធនកម្មមាត្រា១ មាត្រា៣ មាត្រា៤ មាត្រា៧ មាត្រា៨ មាត្រា៩ មាត្រា១១ មាត្រា១៣ មាត្រា១៤ មាត្រា១៥ មាត្រា១៧ មាត្រា១៨ មាត្រា១៩ មាត្រា២០ មាត្រា២១ មាត្រា២២ មាត្រា២៣ មាត្រា២៤ មាត្រា៣០ មាត្រា៣៤ មាត្រា៣៧ មាត្រា៣៨ មាត្រា៣៩ មាត្រា៤០ មាត្រា៤១ មាត្រា៤២មាត្រា៤៣ មាត្រា៤៥ មាត្រា៤៦ មាត្រា៤៩ មាត្រា៥៦ និងមាត្រា៥៦ នៃច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ។

៤-ពិនិត្យ និងសម្រេចលើសំណើរបស់គណៈកម្មការទី៧ព្រឹទ្ធសភា សុំដាក់សេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀង ស្តីពីសហប្រតិបត្តិការ វប្បធម៌រវាងរដ្ឋាភិបាលនៃរដ្ឋជាសមាជិក នៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងរដ្ឋាភិបាលនៃសហព័ន្ធរុស្ស៊ី ។

**៣.សម័យប្រជុំវិសាមញ្ញចំនួន ០១លើក ដើម្បី ៖**

ពិនិត្យ និងឲ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី៖

១-វិសោធនកម្មមាត្រា៧៦ និងមាត្រាទាំងឡាយពីជំពូកទី១៥ ដល់ជំពូកទី១៦ ថ្មីនៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ។

២-ការអនុម័តយល់ព្រមលើពិធីសារណាហ្គូយ៉ា ស្តីពីសិទ្ធិទទួលផលពីធនធានសេនេទិក និងការបែងចែកផលប្រយោជន៍ ពីការប្រើប្រាស់ធនធានសេនេទិកដោយស្មើភាព និងសមធម៌ នៃអនុសញ្ញាសហប្រជាជាតិស្តីពីជីវៈចម្រុះ ។

៣-វិសោធនកម្មមាត្រា១ មាត្រា៣ មាត្រា៤ មាត្រា៧ មាត្រា៨ មាត្រា៩ មាត្រា១១ មាត្រា១៣ មាត្រា១៤ មាត្រា១៥ មាត្រា១៧ មាត្រា១៨ មាត្រា១៩ មាត្រា២០ មាត្រា២១ មាត្រា២២ មាត្រា២៣ មាត្រា២៤ មាត្រា៣០ មាត្រា៣៤ មាត្រា៣៧ មាត្រា៣៨ មាត្រា៣៩ មាត្រា៤០ មាត្រា៤១ មាត្រា៤២មាត្រា៤៣ មាត្រា៤៥ មាត្រា៤៦ មាត្រា៤៩ មាត្រា៥៦ និងមាត្រា៥៦ នៃច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ។

៤-ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀង ស្តីពីសហប្រតិបត្តិការវប្បធម៌រវាង រដ្ឋាភិបាលនៃរដ្ឋជាសមាជិក នៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងរដ្ឋាភិបាលនៃសហព័ន្ធរុស្ស៊ី ។

## ៤.គណៈកម្មការជំនាញនានារបស់ព្រឹទ្ធសភា

ក្នុងខែតុលានេះ សមាជិក សមាជិកាព្រឹទ្ធសភា បានបំពេញការងារយ៉ាងសកម្មតាមតួនាទី ភារកិច្ច និងសមត្ថកិច្ចរបស់ខ្លួនប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ដូចខាងក្រោម៖

### ៤.១ មុខងារនីតិកម្ម

-គណៈកម្មការជំនាញបានប្រជុំផ្ទៃក្នុងគណៈកម្មការ និងប្រជុំអន្តរគណៈកម្មការព្រឹទ្ធសភាជាមួយនឹងតំណាងរាជរដ្ឋាភិបាល ដើម្បីពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងច្បាប់ចំនួន០៤ ។

### ៤.២ មុខងារតំណាង

-បានទទួលពាក្យបណ្តឹងចំនួន០៨ករណី និងបានឆ្លើយតបទៅម្ចាស់បណ្តឹងបានចំនួន០១ករណី និងទទួលឯកសារជូនដំណឹងពីក្រសួង-ស្ថាប័នពាក់ព័ន្ធបានចំនួន២០ករណី តម្កល់ទុកមិនចាត់ការចំនួន០១ករណី

-ប្រជុំក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៧ស្តីពី "ការបើកចំហព័ត៌មានសាធារណៈ និងការដោះស្រាយបញ្ហាក្រុមប្រឹក្សាឃុំ-សង្កាត់ និងសហគមន៍ក្នុងដំណើរឆ្ពោះទៅរកអភិបាលកិច្ចល្អ"

-ប្រជុំសមាជិកសភាតំបន់ស្តីពី ការការពារអំពើហិង្សាលើស្ត្រី និងក្មេងស្រី

-ប្រជុំស្តីពីការនាំចេញអង្ករបស់ប្រទេសកម្ពុជាទៅក្រៅប្រទេសនៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-ប្រជុំពិភាក្សាការងារអំពីការត្រៀមដំណើរទស្សនកិច្ចផ្លូវការ ទៅប្រទេសអាល្លឺម៉ង់ ប្រទេសបារាំង និងប្រទេសប៊ែលហ្ស៊ិក

-ប្រជុំដើម្បីត្រៀមចូលរួមមហាសន្និបាតសហភាពអន្តរសភា (IPU) នៅទីក្រុងហ្សឺណែវ ប្រទេសស្វីស នៅសាល២៧ នៃរដ្ឋសភា

-ជួបពិភាក្សាការងារជាមួយនឹងអង្គការ Friedrich Naumann STIFTUNG នៅ Meta House

-ជួបពិភាក្សាការងារជាមួយលោកបណ្ឌិត Daniel Heilmann ទីប្រឹក្សាច្បាប់ជាន់ខ្ពស់អាល្លឺម៉ង់ អមព្រឹទ្ធសភា ស្វែងយល់អំពីតម្រូវការរបស់គណៈកម្មការ

-ជួបពិភាក្សាការងារជាមួយនឹងមន្ទីរពាក់ព័ន្ធ ជាសមត្ថកិច្ចរបស់គណៈកម្មការ ដើម្បីក្តាប់ព័ត៌មានអំពីបញ្ហាប្រឈមនានា នៅខេត្តកំពង់ស្ពឺ

-អនុញ្ញាតឲ្យភ្ញៀវជប៉ុន ចូលជួបពិភាក្សាការងារ

-អនុញ្ញាតឲ្យ Mr. Ma Minggiang អគ្គលេខាធិការមជ្ឈមណ្ឌលចិនអាស៊ាន ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ

-សិក្ខាសាលាស្តីពី " ប្រវត្តិសាស្ត្រ និងបេតិកភណ្ឌខ្មែរ"

ព្រឹទ្ធសភា

អគ្គលេខាធិការដ្ឋាន

លេខ ១៤៨៤ /១១១៤ /អ.ពស/អ.ស-ន.ន.ស

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# លិខិតអម

## សូមគោរពជូន

សម្តេច ចៅហ្វាវាំង វរវៀងជ័យ អធិបតីស្រីឧត្តម ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង

ឯកឧត្តម ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ

ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

ឯកឧត្តម រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

ឯកឧត្តម រដ្ឋមន្ត្រីក្រសួងព័ត៌មាន

| ល.រ | បរិយាយ | ចំនួន | សេចក្តីផ្សេងៗ |
|---|---|---|---|
| ០១ | របាយការណ៍ស្តីពីសកម្មភាពការងាររបស់ព្រឹទ្ធសភា ប្រចាំខែតុលា ឆ្នាំ២០១៤ ។ | ០១ | ដើម្បីគោរពជូនជ្រាបជាព័ត៌មាន ។ |

ភ្នំពេញ, ថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៤

អគ្គលេខាធិការ

អ៊ុំ សារិទ្ធ